PTI0067

## សម្ភាសជាមួយឈ្មោះ អ៊ិត នី ភេទប្រុស អាយុ៥២ ឆ្នាំ

## មុខងារខ្មែរក្រហមៈ កងទ័ពខ្មែរក្រហម

## មុខងារបច្ចុប្បន្នៈ ធ្វើចំការ

## មានស្រុកកំណើតនៅៈ ភូមិអំពង់ ឃុំព្រះបាទជាន់ជុំ ស្រុកគីរីវង្ស ខេត្តតាកែវ

## សព្វថ្ងៃរស់នៅភូមិស្ទឹងថ្មី ឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់

## ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ សោម ប៊ុនថន

០០:៤៧:៤២

**ទំព័រ២១**

ប៊ុនថន : អញ្ចឹងដំបូងខ្ញុំសុំអនុញ្ញាតសម្ភាសន៍លោកពូៗឲ្យខ្ញុំសម្ភាសន៍ទេលោកពូ?

នី : បាទ! សម្ភាសន៍បានយើងមាននៅរឿងខុសត្រូវអី ទុកជូនក្មេងៗជំនាន់ក្រោយ ឲ្យចងចាំដឹងពីការងារដូចថា ពីម៉ាជំនាន់ទៅម៉ាជំនាន់ ដូចថាម៉ាជំនាន់ខ្ញុំពីត្រឹមណាទៅត្រឹមណា អញ្ចឹងទៅឲ្យបានដឹង ក្មេងក្រោយឲ្យយល់ពីទុកលំបាកអញ្ចឹងទៅ ពីជំនាន់ខ្ញុំអញ្ចឹងម៉ោតៗទៅក្មេងដឹងថា គាត់ហ្នឹងបានជួបផលលំបាកវាបេះមួយបេះពីរអញ្ចឹងទៅណា ។

ប៊ុនថន : បាទ! ដំបូងសុំសួរឈ្មោះឈ្មោះលោកពូឈ្មោះអីដែរ?

នី : ខ្ញុំឈ្មោះ អ៊ិត នី ។

ប៊ុនថន : លោកពូអាយុប៉ុន្មានហើយលោកពូ?

នី : ខ្ញុំអាយុ៥២ឆ្នាំហើយ ។

ប៊ុនថន : លោកពូមានស្រុកកំណើតនៅភូមិ ឃុំអីដែរលោកពូ?

នី : ស្រុកគីរីវង្ស ខេត្តតាកែវ ។

ប៊ុនថន : បាទ!ភូមិអីដែរ?

នី : បើយើងរាប់ពីដើមឡើយម៉ោ យើងរាប់ពីភូមិម៉ោវិញ ភូមិអំពង់ ឃុំព្រះបាទជាន់ជុំ ស្រុកគីរីវង្ស ខេត្តតាកែវ នៅព្រំដែនវៀតណាមនោះ ។

ប៊ុនថន : បាទៗ!លោកពូបានរៀនសូត្រដល់ណាដែរ?

នី ៖ ខ្ញុំបានរៀនបើនិយាយរួម រៀនបានថ្នាក់ទី៩ទេ ទី៩ចាស់ ដល់យើងសម័យហ្នឹងយើងកើតសង្គ្រាមហ្នឹងទៅ តាំងពីឆ្នាំ៧០យើងហ្នឹងអត់មានបានរៀនអីតទៀតទេ ព្រោះយើងសង្គ្រាមរហូតម៉ោ ។

ប៊ុនថន ៖ ឈប់តាំងពីហ្នឹងម៉ោ?

នី ៖ បាទ! ឈប់តាំងពីហ្នឹងម៉ោ ដល់អញ្ចឹងទៅយើងក៏ចូលម៉ោដល់សម័យ៣ឆ្នាំហ្នឹង យើងក៏ទៅជាកងចល័តកងអីអត់មានរៀនសូត្រអីទេ ហើយយើងអត់បានសិក្សាអីបន្តទៀតដែរអាហ្នឹងវាវ័យយើងចេះតែឡើងម៉ោទៀតណាស់ ។

ប៊ុនថន ៖ បាទ! លោកពូមានបងប្អូនប៉ុន្មាននាក់?

នី ៖ ខ្ញុំមានបងប្អូនបើនិយាយរួមទៅវា៨នាក់ទាំងអស់ បងគេខ្ញុំហ្នឹងឯង ម្ដោះហើយវាជួប ផលលំបាកអត់បានរៀនសូត្រទេ ការរត់លូនផង ធ្វើសង្គ្រាមផង យើងធ្វើទ័ពធ្វើអីផងពីសម័យហ្នឹងដំនាន់ហ្នឹងឲ្យតែចេញពីកងចល័តទៅធ្វើទ័ពហ្នឹងហើយ ។

ប៊ុនថន ៖ បាទ! អញ្ចឹងប្អូនៗនៅរស់ទាំងអស់?

នី ៖ នៅរស់រហូតមកដល់សព្វថ្ងៃនេះឯង ។

ប៊ុនថន ៖ បាទ! គាត់រស់នៅណាវិញលោកពូ?

នី ៖ នៅស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ខ្លះនៅយើងក្រុងព្រះសីហនុនោះ វាបែកៗគ្នា ដែរ ។

ប៊ុនថន ៖ បែងបែកគ្នាទៅ?

នី ៖ បាទ! អានេះឆ្លងទៅតាមជីវភាពរបស់ខ្លួន យើងស្រឡាញ់កន្លែងណាតំបន់ណាយើងទៅនៅតាម ឧទាហរណ៍ថាគ្រួសាយើង យើងមានគ្រួសារនៅស្រុកហ្នឹងអញ្ចឹងទៅយើងទៅរស់នៅជាមួយប្រពន្ធកូនអញ្ចឹងទៅ ខាងម្ដាយឪពុកក្មេកអញ្ចឹងទៅ អាខ្លះម៉ោខាងបង្កើតអញ្ចឹងទៅ វាជារឿងធម្មតាផ្ទាល់ខ្លួនរបស់យើងទេ ការជ្រើសរើសរបស់យើងផ្ទាល់ ដែរ ។

ប៊ុនថន ៖ បាទ! លោកពូឪពុកម្ដាយពូនៅរស់ទេ?

នី ៖ ស្លាប់អស់ហើយខ្ញុំ ។

ប៊ុនថន ៖ គាត់ស្លាប់ដោយសារអីដែរលោកពូ?

នី ៖ គាត់ស្លាប់ដោយសារចាស់ជរាហើយ ព្រោះពីសម័យ៣ឆ្នាំហ្នឹងគាត់លត់ដំការងារគាត់វាហត់នឿយអញ្ចឹង ដល់យើងរួចពីហ្នឹងម៉ោ ពី៧៩ហ្នឹងម៉ោវាមិនទាន់មានគេហៅថាគ្រប់គ្រាន់ ដែរវាថ្នាំសង្កូវក៏វានៅខ្វះខាតច្រើនអញ្ចឹងទៅ យើងអត់មានមន្ទីរពេទ្យអីជិតដល់ដូច យើងសម័យឥឡូវនេះទេ ពីមុនម៉ោហ្នឹង និយាយរួមដូចថានៅខ្វះខាតភ្លាមៗ ហ្នឹងពី

សម័យសង្គ្រាមហ្នឹងក៏គាត់បានស្លាប់ទៅ រួចពីសង្គ្រាមហើយហ្នឹងចាស់ជរា គាត់អាយុ ៨០ជាងហើយបានគាត់ស្លាប់ទៅ ។

ប៊ុនថន : ស្លាប់ទាំង២នាក់ហ្នុងលោកពូ?

នី : ស្លាប់ទាំង២ ប៉ុន្តែមិនស្លាប់ជាមួយគ្នាបន្ទាន់ៗទេ មានមុនក្រោយគ្នា ៣-៤ឆ្នាំអញ្ចឹងទៅ បានគាត់ស្លាប់ទៅ គាត់ចាស់ហើយ ។

ប៊ុនថន : បាទ!គាត់ទឹមស្លាប់ក្រោយទេ មិនមែនស្លាប់សម័យ៣ឆ្នាំទេ ។

នី : បាទ! មិនមែនទេគាត់ទឹមស្លាប់ ។

ប៊ុនថន : អញ្ចឹងលោកពូសុំសួរបន្តទៀត ពូក្រោយពីឈប់រៀនហ្នឹងពូធ្វើអីបន្តទៀត?

នី : ឈប់រៀនហ្នឹងពីសម័យ៧៩ហ្នឹងគឺចូលសម័យ៣ឆ្នាំហ្នឹង សម័យប៉ុល ពត ។

ប៊ុនថន : ឆ្នាំ៧០លោកពូ ពេលពូឈប់រៀនភ្លាមសម័យរដ្ឋប្រហារលន់ ណុល ?

នី : បាទៗ!អាហ្នឹងយើងចូលម៉ោខ្មែរក្រហមហ្នឹងយើង គេនៅខាងក្នុងៗ យើងនៅខាងខ្មែរក្រហមៗអញ្ចឹងទៅ យើងអត់មានបានរៀនសូត្រអីទេយើងនៅកងចល័តអញ្ចឹងទៅ ។

ប៊ុនថន : ចូលកងចល័តលោកពូ?

នី : បាទ!ចូលកងចល័ត ។

ប៊ុនថន : កាលនោះគេប្រមូលម្តុំ គេបែងចែកយ៉ាងម៉េចទៅចូលកង?

នី : កងចល័តឧទាហរណ៍ខាងយុវជនគេទៅជីកប្រឡាយជីកអីអញ្ចឹងទៅ យើងធ្វើទំនប់អីទៅ ជីកវែកដីយើងទប់ទំនប់អញ្ចឹងទៅ ដល់ម៉ោងហូបបាយចែករបបឲ្យយើងហូបអញ្ចឹងទៅ ដល់ពេលរួចអញ្ចឹងម៉ោយើងត្រូវធ្វើយប់ៗ ថ្ងៃៗទៅតាមកំណត់ម៉ោងរបស់គេ ។

ប៊ុនថន : បាទ! កាលហ្នឹងប្រមូលចូល ឬក៏យើងចងជាក្រុមជាអី?

នី : គេមានក្រុមគេ មានកងគេត្រឹមត្រូវហ្នុង ដូចថាក្នុងសង្គមហ្នឹងគេរៀបរយអញ្ចឹងទៅ ទាំងអស់ហ្នុង កងចល័តអញ្ចឹងៗទៅ យុវជនៗអញ្ចឹងទៅ នារីៗអញ្ចឹងទៅ អញ្ចឹងគេរៀបក្រុមអញ្ចឹងទៅកងគេអញ្ចឹងទៅ វាដល់ម៉ាកងគេហ្នឹងមានប៉ុន្មានក្នុងម៉ាស្រុកអញ្ចឹងទៅវាមានកងចល័តគេដាក់ម្តុំអញ្ចឹងទៅ ប៉ុន្តែគេបែងចែកកន្លែងការងារទៅធ្វើតាមការដ្ឋានគេណាណីធ្វើទៅ ទៅធ្វើការដ្ឋានណាយើងនាំគ្នាទៅហ្នឹងយើងវែកថែប វែកអីលីចបបង្គីរទៅធ្វើទៅដូចថា ហ៎!ទៅធ្វើទំនប់ហ្នឹងទៅនោះទៅអញ្ចឹងទៅ ។

ប៊ុនថន : អញ្ចឹងពេលរដ្ឋប្រហារភ្លាមហ្នឹង ខាងពូហ្នឹងខាងក្រៅខាងខ្មែរក្រហមអី?

នី : បាទៗ! ខាងខ្មែរក្រហម ។

ប៊ុនថន : ខាងខ្មែរក្រហមចូល?

នី : បាទ! អាហ្នឹងនិយាយរួមទៅខាងខ្មែរក្រហមរំដោះ កន្លែងណាដូចក្រុងអញ្ចឹងគេមិនទាន់រំដោះគេនៅដូចថា តាមក្រុមគេធំៗអញ្ចឹងទៅ ដូចភ្នំពេញអញ្ចឹងទៅ ដូចតាកែវអញ្ចឹងទៅគេមិនទាន់រំដោះបាន យើងអ្នករំដោះបានយើងចេញម៉ោក្រៅទៅជាមួយទ័ពអញ្ចឹងទៅជាមួយប្រជាពលរដ្ឋអញ្ចឹងទៅ ជាមួយយុវជន យុវនារីអញ្ចឹងទៅ ដល់ពេលយើងផុតពីយុវជនហ្នឹងទៅគេរើសចូលកងទ័ព យើងចូលកងទ័ពបំរើជាតិអញ្ចឹងទៅ អាហ្នឹងគេទៅតាមសង្គម ។

ប៊ុនថន : ពូចូលកងទ័ពរំដោះភ្នំពេញហើយឬក៏ចូលឆ្នាំ?

នី : ខ្ញុំបើនិយាយរួម ចូលកងទ័ពរំដោះភ្នំពេញហើយ ។

ប៊ុនថន : ឆ្នាំប៉ុន្មានលោកពូប្រហែល?

នី : យី!ដូចជាភ្លេចដែរ វាយូរដែរហើយយើងអត់បានចាំ យើង៧៥រំដោះភ្នំពេញ ។

ប៊ុនថន : បាទ! ១៧ មេសា ១៩៧៥?

នី : តែខ្ញុំហ្នឹងវាមុនហ្នឹង យើងលើកទៅខាងខ្មែរក្រហមមុនហ្នឹង ប្រហែលវា៧៣អីហ្នឹងទេ ។

ប៊ុនថន : ៧៣ពូចូលកងទ័ព?

នី : ចូលកងទ័ពៗបំរើហ្នឹង យើងនៅព្រំដែនហើយ ឈរជើងបាញ់គ្នាជាមួយយួនជាមួយអីអញ្ចឹងកាលពីសម័យហ្នឹងយើងសត្រូវគ្នាជាមួយយួននោះ ខ្មែរក្រហមនឹងយួនវាមានត្រូវគ្នាណា?

ប៊ុនថន : បាទៗ! ចូលហ្នឹងចូលច្រើនគ្នាទេពូ?

នី : ចូលដូចតាមសមត្ថភាពយើងដែរ និយាយរួមគេជ្រើសរើសដូចថាអ្នកចាស់អញ្ចឹង អ្នករំដោះបានយូរហើយគេ ខ្ញុំចង់និយាយថាយើងអ្នកមូលដ្ឋាន អ្នកមូលដ្ឋានហ្នឹងគឺអ្នករំដោះមុន ហើយអ្នករំដោះក្រោយនេះគេហៅអ្នក១៧មេសាអញ្ចឹងទៅ អ្នក១៧មេសាហ្នឹងគេអត់មានចូលទេ យើងអ្នកមូលដ្ឋានយើងចូលមុនទៅបំរើកងទ័ពនោះ ។

ប៊ុនថន : បាទ! ចូលហ្នឹងគេជ្រើសរើសម៉េចពូ ប្រធានក្រុមប្រធានភូមិអ្នកជ្រើសរើស?

នី : អាហ្នឹងតាមភូមិ តាមកងគេហ្នឹងគេរៀបឲ្យយើងចូលដូចថាយើងឈ្មោះយើងដល់អាយុយើងដល់អញ្ចឹងទៅ គេរៀបចូលយើងទៅចូលទៅ ក្នុងអង្គភាពហ្នឹងទៅបំរើជាតិ ទៅយើងទៅហាត់ទៅហ្វឹកហ្វឺនកាន់អាវុធទៅ ផ្ញើសត្រ្គាមបន្តៗគេឯងវ៉ៃយួនវ៉ៃអីទៅដល់ពេលយួនបុកម៉ោយើងរត់ម៉ោៗ ។

ប៊ុនថន : ចូលដំបូងចូលនៅណាវិញលោកពូ?

នី : ខ្ញុំចូលនៅភូមិ ស្រុកខ្ជូនឯងហ្នឹងហ្មង រៀបចំនៅហ្នឹងចុះអាហ្នឹងគេរៀបចំតាមមូលដ្ឋានយើងនៅណាយើងធ្វើនៅហ្នឹងដែរ ។

ប៊ុនថន : បាទ! ចូលបានយូរទេ?

នី : ពីសម័យហ្នឹងយើងចាប់បញ្ចូលៗគ្មានបានយូរប៉ុន្មានទេ មួយខែពីរខែហ្នឹងយើងអាចទៅធ្វើសង្គ្រាមបាន កាន់អាវុធបាញ់គ្នាទូងទាំងបាត់ហើយ អត់បានយូរទេពេលហ្នឹង ។

ប៊ុនថន : ហាត់ហ្នឹងហាត់របៀបអីខ្លះ?

នី : ហាត់យើងបច្ចេកទេសរៀនបាញ់ រៀនដោះមីនអញ្ចឹងទៅណ៎ា រៀនប្រយុទ្ធរៀនឡើងបាញ់អញ្ចឹងទៅ វារបៀបបច្ចេកទេសសង្គ្រាមនោះណា ស្ទាក់បាញ់លួចបាញ់ពីខាងពីក្បៀនអញ្ចឹងទៅឬក៏ពីមុខទៅ អ្នកចំមុខៗទៅ អ្នកឡើងបាញ់ពីខាងៗទៅអាហ្នឹងអ្នកបច្ចេកទេសខាងសង្គ្រាមអាហ្នឹង ។

ប៊ុនថន : បាទ!ហើយលោកពូចូលដំបូង គេបែងចែកមានកងមានអីទេកាលហ្នឹង?

នី : ជាកងដែរ គេរៀបកងរៀបពួក ទី១គេរៀបពួក ពួកហើយបានរៀបក្រុម ក្រុមហើយបានជាកងធំអាហ្នឹងមានអង្គភាពគេនោះ រៀបអង្គភាពរៀបអីដូចយើងទាហានឥឡូវៗហ្នឹងដូចគ្នាហ្នឹង ។

ប៊ុនថន : ពូនៅក្រុម នៅកងអីប៉ុន្មានកាលហ្នឹងដំបូង?

នី : កាលហ្នឹងគេហៅ១០៥ វរៈសេនាធំ១០៥ ។

ប៊ុនថន : វរៈសេនាធំ១០៥?

នី : បាទ! កងពលលេខ២ បើវរៈសេនាតូចគេហៅថា១៤ ។

ប៊ុនថន : បាទ!ចុះអ្នកនេះពូ?

នី : ប្រធានវរៈនោះឈ្មោះ វ៉ាន ប្រធានវរៈសេនាធំឈ្មោះ តានាគ ។

ប៊ុនថន : តានាគ?

នី : បាទ!

ប៊ុនថន : ចុះប្រធានកងពល?

នី : កងពលដូចអត់សូវបានស្គាល់ច្បាស់ប៉ុន្មានទេ ដូចយើងនៅពាក់ពើនៅឡើយយើងចូលភ្លាមៗយើង ដល់ពេលអញ្ចឹងយើងរត់លូនទៅយើងបែកសាចគ្នាទៅ យើងក៏មិនសូវបាននៅជិតគេដែរ ។

ប៊ុនថន : ចុះគាត់នៅរស់ដែរប្រធានកង?

នី : អេ៎!វាអត់ដឹងយ៉ាងម៉េចដែលអូន វារយៈកាលកន្លងផុតយូរមកហើយពីសម័យសង្គ្រាម ហ្នឹងវាបែកបាក់គ្នាត្រូវខ្ចាត់ខ្ចាយម៉ោខាងនោះម៉ោៗខាងហ្នឹងម៉ោ ឆ្លងផ្លូវជាតិលេខ៤ ម៉ោ ខ្ញុំឆ្លងអត់ផុតអញ្ចឹងខ្ញុំវិលទៅវិញអញ្ចឹងទៅ ហើយយួនដេញស្ទាក់អញ្ចឹងទៅ យើងដាច់ទៅនោះវិញទៅគេម៉ោផុតម៉ោ គេម៉ោដូចបងៗសព្វថ្ងៃគាត់នៅដែលចាស់ៗ ម៉ា ស្រុករខ្ញុំដែលប្អូក៏ចាស់ជាងខ្ញុំហ្នឹង គាត់ម៉ោដូចថាម៉ោតាមព្រំដែនអញ្ចឹងម៉ោ ចាប់ពីយើងលាជ គេហៅស្រុកលាជៗពីមុនដំបូង មិនមែនស្រុកក្រវាញទេគេហៅស្រុក លាជៗ ហើយយើងឆ្លងពីហ្នឹងម៉ោស្រីមល ស្រងាម់ជ្រុលអីអញ្ចឹងម៉ោផ្លូវជាតិលេខ៤ ម៉ោ ឆ្លងម៉ោហ្នឹងម៉ោបានកងទ័ពគេរៀបចំប្រមូលផ្ដុំគ្នាមួយសារទៅ ម៉ោជុំអញ្ចឹងទៅក៏បែងចែកជាកម្លាំងតទៅទៀតទៅ ហើយដល់អញ្ចឹងទៅក៏វា រួចពីហ្នឹងទៅមិនដឹងក៏អ្នកណាមួយស្លាប់ អ្នកណាមួយរស់ក៏បែងគ្នាទៅ យើងនៅក្មេងៗដែរពីជំនាន់អស់ហ្នឹង ហើយដល់អ្នកម៉ោពីហ្នឹងគេធ្វើការគេមេៗនោះ មេធំៗទៅយើងនេះក៏អត់ទៅក៏បម្រើកងទ័ពខាងពី៧៩ហ្នឹងយើងចូលកងទ័ពទៀតហើយហ្នឹង អាហ្នឹងចូលខាងអីគេហៅថាភ្លូចកងទ័ពហ្នឹងមិនដឹងឈ្មោះអីទេ យើងស្ម័គ្រចិត្តចូលកងទ័ពរើសថ្មីមួយសារទៀត ប្រទេសកម្ពុជាយើងដែលទទួលបានជ័យជំនះហើយ ពី៧៩ហ្នឹងយើងចូលកងទ័ពទៀត ទៅ ។

ប៊ុនថន : បាទ!ខាងក្នុងឬខាង?

នី : ខាងក្នុងកងទ័ពយើងរាល់ថ្ងៃលោក ហ៊ុន សែនហ្នឹង ចូលខាងហ្នឹងចូលបាន១ឆ្នាំជាង ដែលខ្ញុំចូល២ឆ្នាំហើយយើងថា២ឆ្នាំចុះ ចូលហ្នឹងខ្ញុំនៅស៊ីងប្រាលនោះបង្កើតកងពល នៅហ្នឹងកងពលលេខ២ កងពលចាស់ហ្នឹង ។

ប៊ុនថន : កងពលលេខ២?

នី : បាទ!កងពលលេខ១នៅភ្នំពេញ ខ្ញុំនៅហ៊ុកហ៊ឺនហាត់ទ័ពអីហ្នឹងរៀបកម្លាំងរៀបអី ខ្ញុំអត់មានរៀបទេគឺថា ផ្នែកខាងមេៗគេអ្នករៀបហ្នឹង បញ្ចូលលទ័ពថ្មីទាំងអស់គ្នា រៀបថ្មីទាំងអស់នៅស៊ីងប្រាលហ្នឹង ។

ប៊ុនថន : បាទ! ពីណាអ្នកប្រធាន?

នី : ប្រធានកងពលទី១ តាទីណូ រួចពីតាទីណូម៉ោ ឈ្មោះ ហ៊ុយ វណ្ណាប្រធានកងពល ។

ប៊ុនថន : ប៉ុនឥឡូវគាត់នៅរស់?

នី ៖ គាត់នៅធ្វើការដែល ហ៊ុយ វណ្ណា ប៉ុន្តែមិនដឹងគាត់ធ្វើខាងអីទៀតទេខ្ញុំអត់ដឹងដែរ ឬក៏គាត់ឈប់ទេណា៎! ប៉ុនមិនឈប់ទេ បើនេះក៏រ៉ូត្រែតអីទៅគាត់នៅនេះអញ្ចឹងទៅ គាត់នៅប្រធានកងពលនៅហ្នឹង ។

ប៊ុនថន ៖ សួរត្រឡប់ទៅក្រោយវិញ លោកពូនៅកងនៅតាកែវហ្នឹងឆ្នាំ៧៣ហ្នឹងលោកពូបន្ទាប់ពីហាត់ហើយមានបញ្ជូនទៅវៃអីនៅណា ទៅប្រចាំការណ៍នៅណាទេ?

នី ៖ អាហ្នឹងឈរជើងហ្នុង ទៅប្រចាំការណ៍ហ្នុង ប្រចាំការនៅព្រំដែនវៀតណាម ខ្មែរយើង ហ្នឹងគេនៅម្ខាងយើងនៅម្ខាង នៅម្ខាងព្រែកម្នាក់ហ្នឹងគេនៅខាងនោះទៅទឹកដីគេ យើងនៅទឹកដីយើង ប៉ុនបើតំបន់នោះគេមានជីកព្រែកមួយ ព្រែកជីកហ្នឹងសម្រាប់តែតំបន់គេផ្សេង តំបន់យើងផ្សេង យើងការពារតំបន់យើងអញ្ចឹងហ្នុង ។

ប៊ុនថន ៖ ទ័ណ្ឌពីវៀតណាម ជាមួយខ្មែរលោកពូ?

នី ៖ បាទ! ជាមួយខ្មែរ ប៉ុននៅតែបាញ់គ្នាហ្នឹងទៅមកៗអញ្ចឹង បាញ់ស៊ីគ្នាហ្នឹងទៅមកហ្នឹងយើង ខែទឹកអីយើងអុំទូកទៅវាបាញ់យើងទៅ វាអញ្ចឹង ហើយយើងជីកប្រែកតាមខ្នងព្រំដែនព្រែកជីកហ្នឹង យើងធ្វើអាប្រែកត្រឹមត្រូវសុទ្ធតែធំៗណាស់វាបាញ់មិនចូលទេ ។

ប៊ុនថន ៖ ព្រែកជីកគេហៅឈ្មោះអីវិញ?

នី ៖ ព្រែកជីកហ្នឹងគេហៅថា នៅព្រំប្រទល់យើងនឹងវាឈរជើងទល់មុខហ្នឹងគេហៅថាសំបុកមាន់ ឃុំតាភរយើងប៉ែកមកខ្មែរយើងនេះ មកក្រោយនេះឃុំតាអូរ តែស្រុកគិរីវង្សដែរ សោមតាអូរហ្នឹង ទ័ពហ្នឹងឈរជើងតាសោមហ្នឹង ។

ប៊ុនថន ៖ បាទ!អញ្ចឹងវាយគ្នាជាមួយវៀតណាមហ្នឹង អញ្ចឹងវាយគ្នាតាំងពី៧៣ម៉ោ ទៅវិញទៅមកទៀត?

នី ៖ បាទ! វាយគ្នាទៅវិញទៅមកៗទៀត ។ ៧៣កាលហ្នឹងវៀតណាមត្រូវចុះត្រឡប់ទៅពីស្រុកខ្មែរទៅវិញ ខ្មែរក្រហមបានជំនួយពីវៀតណាមម៉ោដែរ ដូចវៀតណាមវាចង់យកទឹកដីខ្មែរ អញ្ចឹងខ្មែរក្រហមវាដឹងខ្លួនវាដេញវៀតណាមទៅវិញ វាដេញទៅដេញមកៗអាហ្នឹងបើនិយាយរួមទៅ អានេះជារឿងផ្ទៃក្នុងអ្នកធ្វើសង្គ្រាមយើងអត់ដឹងនិយោគបាយដែលគេឈ្លានពានយើងម៉េចៗទេ ប៉ុនដែលយើងដាក់ៗហ្នុង យើងបាញ់ៗហ្នុង ។

ប៊ុនថន ៖ បាទ!អញ្ចឹងនៅហ្នឹងវៃជាមួយវៀតណាមផង ជាមួយលន់ ណុលផង?

នី ៖ អត់ទេៗ!ដាច់ដោយឡែកៗពីគ្នា រឿងលន់ ណុលផ្សេងទេ លន់ ណុពីមុនហ្នឹងទៀត ។

ប៊ុនថន ៖ អូ!អញ្ជឹងពូនិយាយហ្នឹងក្រោយបន្ទាប់ពីរំដោះភ្នំពេញហើយ?

នី ៖ បាទ!អាហ្នឹងយើងរំដោះភ្នំពេញហើយក្រោយនោះទេ ពេលយើងរំដោះភ្នំពេញហើយ ហ្នឹងបើនិយាយរួមក្រោយមកហ្នឹងវា៧៦-៧៧ហើយបានយើង ។

ប៊ុនថន ៖ អញ្ជឹងពូទៅប្រចាំការណ៍នៅហ្នឹង៧០ប៉ុន្មានពូ?

នី ៖ ៧៦-៧៧ហ្នឹងហើយ ។

ប៊ុនថន ៖ ទៅប្រចាំការណ៍នៅវត្តព្រែក នៅខាង?

នី ៖ បាទៗ! ៧៦-៧៧ហ្នឹង ។

ប៊ុនថន ៖ អញ្ជឹងខ្មែរក្រហមរំដោះភ្នំពេញហើយ?

នី ៖ បាទៗ! បើនិយាយពី៧៣នោះមិនទាន់ នោះយើងនៅជាកងចល័ត កងអីនៅអីទេអា ហ្នឹងនោះ ។

ប៊ុនថន ៖ បាទ!អញ្ជឹងពូថាចូលកង ចូលហ្វឹកហាត់ទាហានឆ្នាំ៧៣លោកពូ?

នី ៖ អេ!អត់ទេចូលកងចល័ត៧៣ហ្នឹង យើងចូលកងហ្វឹកហាត់ហ្នឹងវាផ្សេងទេអាហ្នឹង វា ទៅជាកងព្រលិតកងអីអាហ្នឹងគេរៀបកងព្រលិត កងឈ្លបកងអីហើយអាហ្នឹងប៉ុនយើង នៅតែទ័ពហ្នឹងវា យើងតាមស្រុកភូមិគេរៀបចំគេហៅថា កងឈ្លប កងអីអញ្ជឹង ។

ប៊ុនថន ៖ បាទ! អញ្ជឹងពេលនោះអត់ទាន់គេវៃទេ?

នី ៖ អត់ទាន់មានគេវៃទេ អាហ្នឹងគេថាគ្រាន់តែគេពង្រឹងនៅក្រោយអញ្ជឹង អត់ទាន់ទេ ដល់ យើងពង្រឹងហើយ វាចេញពីហ្នឹងមកគេឲ្យយើងទៅការពារនៅព្រំដែនហ្នឹងបណ្ដោយ ទៅបាញ់គ្នាហ្មង គ្មានទៅការពារទេទៅបាញ់ហ្មងហ្នឹង ទៅប្រយុទ្ធហ្មងហ្នឹង ។

ប៊ុនថន ៖ ចុះមុនហ្នឹងពូថានៅកងឈ្លបនៅអីហ្នឹង អត់ទាន់បានឡើងវៃជាមួយ លន់ ណុលអីទេ?

នី ៖ អត់ទេៗ! អត់ដែលឡើងវៃទេ ការពារតែភូមិឃុំហ្នឹង ។

ប៊ុនថន ៖ អញ្ជឹងពូនៅរហូតដល់រំដោះហើយ?

នី ៖ បាទ!ធ្វើកងទ័ពរហូតដល់រំដោះ ដេញរបាំត់របាយមកបានថាវាម៉ោរហូតដល់កងទ័ព យើងម៉ោខាងនេះទៅ យើងទៅនោះវិញទៅ ដល់យើងវាសន្តិភាពទៅវាចូលកងទ័ពខាង នោះវិញ ។

ប៊ុនថន ៖ បាទ! ចុះរំដោះភ្នំពេញហ្នឹងលោកពូដឹងទេ ដឹងថាគេរំដោះទេ?

នី : ដឹងដែរ អាហ្នឹងយើងពួក១៧/គេបែងចែក១៧ ហើយនឹងអ្នកចាស់អ្នកថ្មីអាហ្នឹង អាហ្នឹងគេរំដោះពីសម័យហ្នឹងម៉ោ ។

ប៊ុនថន : អញ្ចឹងពេលរំដោះបានហ្នឹងពូនៅក្នុងភូមិពូដដែល?

នី : បាទ! យើងនៅដែរហ្នឹង ប៉ុន្តែពីសម័យហ្នឹងយើងអត់នៅភូមិហ្នឹង យើងនៅហ្នឹងដដែល ទេណា៎! យើងផ្លាស់ទីលំនៅ ឧទាហរណ៍ថាយើងទៅនៅឃុំផ្សេងអញ្ចឹងទៅ គេប្រមូលម្តុំទៅកងចល័តទៅនៅផ្សេងអញ្ចឹងទៅ ។អាហ្នឹងផ្សេង ដល់ពេលយើងអាអងភាពយើង យើងទៅជាឈ្លបទៅជាអីនោះអាហ្នឹងរឿងផ្សេងទៀត អាហ្នឹងបែងចែកវាមានដែន របស់វា ។

ប៊ុនថន : ចុះពូម៉ោទៅនៅភូមិណា?

នី : ខ្ញុំម៉ោនៅយើងស្រុក១០៥ គេហៅស្រុក១០៥ ស្រុកនៅខាងលិចអន្លង់សោមនេះ អន្លង់ការអន្លង់អីនេះ ។

ប៊ុនថន : អន្លង់ការ?

នី : បាទ! អន្លង់ការខាងលិចអន្លង់សោម ។

ប៊ុនថន : ឥឡូវគេហៅស្រុកអីវិញពូ?

នី : ហ្នឹងនៅស្រុកត្រាំកក់ ខេត្តតាកែវដែរ ។

ប៊ុនថន : បាទ!ចុះពូម៉ោនៅហ្នឹង?

នី : ខ្ញុំនៅហ្នឹងបាន វាត្រឡប់ត្រលិនណាស់ពីសម័យហ្នឹងនោះ យើងពិបាកសន្និដ្ឋានដែរ សម័យហ្នឹង អញ្ចឹងហើយយើងទៅនៅស្រុក១០៥ហ្នឹងយើងគេរំដោះ យើងភៀសខ្លួន ៗហ្នឹងគេរំដោះ រៀបរយហ្នឹងចងជាក្រងភូមិ ឃុំ ក្រុមអីអញ្ចឹងទៅយើងស្ម័គ្រចិត្តធ្វើ កងទ័ព ធ្វើឈ្លបអីចេះតែធ្វើគេឯងទៅ ដល់ពេលយូរៗទៅ គេរុញម៉ោភូមិម៉ោស្រុក វិញម៉ោ តាមភូមិតាមស្រុកចាស់យើងវិញកាលហ្នឹង វាអាទៅហើយម៉ោៗវាត្រឡប់ ត្រលិនកាលហ្នឹង អញ្ចឹងក៏យើងវិលម៉ោវិញម៉ោៗទៅតាមកងចល័ត ទៅតាមអីអញ្ចឹង ដល់ចេញពីកងចល័តហ្នឹងម៉ោចូលទ័ពវិញទៅវាត្រឡប់ត្រលិនណាស់ វាមិនមែនថា យើងនឹង ធ្វើប្រវត្តិរូបយើងចេះចុះអី គេលើកទៅតាមថ្នាក់យើង ត្រង់នេះត្រង់នោះ អត់ទេ គេចាប់ញូល ។

ប៊ុនថន : អញ្ចឹងលោកពូទៅនៅស្រុក១០៥ហ្នឹងបានយូរទេលោកពូ ។

នី : ខ្ញុំទៅនៅហ្នឹងបានជិត១ឆ្នាំ យើងថា១ឆ្នាំចុះ ។

ប៊ុនថន : ទៅហ្នឹងធ្វើអីវិញលោកតូ?

នី : ទៅហ្នឹងយើងនៅកងចល័ត ប៉ុនកងចល័តពីសម័យហ្នឹងសម័យរណសិរ្សរួបរួមជាតិ ដូចប្រវាសដៃធ្វើស្រែធ្វើអីអាហ្នឹង កត់តែឈ្មោះទេ ប៉ុនយើងអត់ទាន់ចេញដើរតួរជា ដឹកប្រឡាយដឹកអីទេ អាហ្នឹងពីមុនម៉ោះនោះ ក្រុមប្រវាសដៃទេ អាហ្នឹងវាអត់ទាន់ហូប រួមទេកាលហ្នឹងនោះ ។

ប៊ុនថន : ហើយនៅហ្នឹងហើយបានត្រឡប់ម៉ោគីរីវង្សវិញ?

នី : បាទ! ត្រឡប់ម៉ោគីរីវង្សហើយ បានចូលបាយរួមបាយអី តាមសហករណ៍តាមអីទៅ បែងចែកកងចល័តមួយសារទៀតទៅ អាហ្នឹងវារៀបតាមវគ្គៗវាអញ្ជឹងទៅ ។

ប៊ុនថន : កងចល័តហើយបានពូចូលទ័ព?

នី : បាទ! ចូលទ័ព ។

ប៊ុនថន : ចូលទ័ពហ្នឹងគេចាត់តាំងឲ្យពូទៅ ព្រំដែនវិញ?

នី : បាទ! យើងចូលទៅខ្លួនយើងៗដឹងតែបំរើជាតិហើយ ។

ប៊ុនថន : បាទ! កាលហ្នឹងគេជ្រើសរើស ឬយើងស្ម័គ្រចិត្តកាលហ្នឹង?

នី : អ៎! កាលហ្នឹងអត់មានស្ម័គ្រចិត្តទេ គេជ្រើសរើស ។

ប៊ុនថន : ខាងណាជ្រើសរើសពូ?

នី : កាលហ្នឹងតាមភូមិ តាមស្រុកគេហ្នឹងគេផ្តល់ម៉ោអង្គភាពដូចថា គេហៅកងចល័តអញ្ជឹង គេមានមេប្រធានកងចល័តគេ គេរើសយើងទៅ គេថាឈ្មោះយើងត្រូវទៅទ័ពអញ្ជឹង យើងទៅៗ ដល់ឈ្មោះខ្ញុំនេះមួយគេថាហ៎! ទ័ពហ្នឹងឈ្មោះប្អូនឯងមួយអញ្ជឹងដែរទៅ កងចល័តដូចគ្នាទៅទ័ពទៅ ទៅគេអញ្ជឹងទៅ គេបើកខោអាវពាក់ទូនាប់ដើងទៅប៉ុចទៅ ក្រស្បែងបង់ក ពាក់មួកទៅ ។

ប៊ុនថន : ប៉ុនចង់ទៅទេពូ ដូចថានៅនោះគេមានក្មេងដែរ?

នី : អ៎!រឿងមិនចង់គ្មានទេ វាត្រូវតម្រូវឲ្យទៅអញ្ជឹងហ្មង ឲ្យទៅណាទៅហ្នឹងហើយកាល ហ្នឹង អត់មានយើងថាមិនប្រកែកទេ ប្រកែកអត់បានទេ ។

ប៊ុនថន : ដូចឃើញមានខោអាវថ្មី?

នី : បាទ! ហើយកាលហ្នឹងយើងគ្មានខោអាវស្លៀកពាក់បានល្អផង ទៅកងទ័ពទៅមានខោ អាវថ្មីពាក់ ហើយសំខាន់បំផុតទី១យើងជីវភាពយើងនៅកងចល័តវាអត់គ្រប់គ្រាន់អួន ណាស់ យើងចែកបបរចែកអីហូបអញ្ជឹងវាអត់គ្រប់គ្រាន់ ហើយពលកម្មយើងក៏វា

ឡើយដែរ ដល់អញ្ចឹងយើងទៅកងទ័ពទៅ រឿងហូបវាជារឿងធម្មតាដែរទេ អញ្ចឹងមនុស្សម្នាក់ៗបេះតែចង់ទៅហើយ វាសំខាន់ទាមទាររឿងឆ្អែតហ្នឹងហ្នង ។

ប៊ុនថន : បាទ! ចូលដំបូងហ្នឹងពូមុនហ្នឹងប្រាប់ខ្ញុំម្ដងហើយថា ចូលទៅកងវរៈប៉ុន្មានពូ?

នី : ចូលទី១ នៅកងវរៈសេនាធំ១៦ ប៉ុនដល់យើងនៅវរៈសេនាតូចនេះគេហៅផ្សេងៗទេអាហ្នឹង ដល់កងពលៗលេខ២ ។

ប៊ុនថន : អញ្ចឹងទៅភ្លាមហ្នឹងពូទៅប្រចាំការណ៍នៅនោះភ្លាម?

នី : គេឲ្យនៅក្រោយ វាអត់ទាន់ទៅធ្វើសង្គ្រាមទៅដល់សង្គ្រាមទេ អាហ្នឹងគេមានកន្លែងអ្នកគេទៅចូលដំបូងគេបេះតែនៅហាត់ហ្វឹកហ្វឺនក្រោយគេ កន្លែងទ័ពដែរ ប៉ុនម៉ោខាងក្រោយកន្លែងហាត់ កន្លែងហ្វឹកហ្វឺនគេហ្នឹង ដល់ពេលយើងបានប៉ុន្មាន ឧទាហរណ៍ថា ២-៣-៤ខែអញ្ចឹងទៅ មើលតែគេត្រូវការយើងទៅមុខគេទៅអាហ្នឹងអញ្ចឹង ទៅមុខហ្នឹងសុទ្ធតែឈរមុខហើយ ។

ប៊ុនថន : បាទ! អ្នកណាអ្នកបង្ហាត់វិញពូ?

នី : អេ៎!ជំនាញគេហើយ អ្នកហ្វឹកហ្វឺនគេជំនាញគេវា ដូចថាតាមកង តាមវរៈអញ្ចឹងទៅនៅនោះ អញ្ចឹងដូចថាអ្នកហ្នឹងគេអ្នកចាស់មុនអញ្ចឹងគេឲ្យខាងបង្ហាត់ទ័ពអញ្ចឹងទៅ អាហ្នឹងកងវរៈសេនាតូច ហើយដល់អញ្ចឹងទៅយើងហាត់ហើយបានគេឲ្យទៅទៀតទៅ ថាហ៎!វរៈសេនាតូចទីប៉ុន្មានអញ្ចឹងទៅ ត្រូវទៅកម្លាំងដែលហាត់ហ្នឹងបានចំនួនប៉ុន្មានដែលវគ្គមុនហ្នឹងឲ្យទៅមុខហ្នឹងបណ្ដោយ អ្នកក្រោយនៅហាត់ក្រោយទៀតទៅ បន្តៗគ្នាវាមិនខុសទ័ពយើងឥឡូវទេ វាដូចតែគ្នាហ្នឹងបច្ចេកទេសនោះ វាមិនខុសគ្នាទេ យើងមិនមែនចូលទៅដល់កាន់អាវុធភ្លាមនោះទេ ។

ប៊ុនថន : ហាត់សិន?

នី : ហាត់សិន ដល់ហាត់អញ្ចឹងទៅយើងទម្រាំសិក្សាបានគ្រប់គ្រាន់ហើយបានឲ្យទៅប្រយុទ្ធ ហ្នងប៉ុនអាវុធពីសម័យហ្នឹងកាន់តែរហូតហ្នឹង ឥឡូវហ្នឹងក៏យើងនៅតែកាន់ដែលទាហានក៏នៅតែកាន់ដែលមិនអត់ទេ ឲ្យតែយើងចូលក្នុងអង្គភាពកាន់ហើយ មិនអត់ទេ ប៉ុនយើងនៅក្នុងហ្វឹកហ្វឺន ។

ប៊ុនថន : អញ្ចឹងគេចែកអាវុធឲ្យហ្នឹងសម្រាប់ហាត់ សម្រាប់បាញ់?

នី : បាទ!មិនមែនយើងដើរបាញ់តែពីពាសអីអត់ទេ យើងគ្រាន់តែហាត់តម្រង់ស៊ីបអីទៅហាត់ដោះគ្រាប់ដោះអាវុធដោះអីនោះ យើងរៀបអាវុធអញ្ចឹង ។

ប៊ុនថន :	បាទ! ម៉ាវគ្គពូចូលហ្នឹងច្រើនទេពូ?

នី :	វាបើនិយាយរួមទៅវាទូទៅគេឲ្យយើងម៉ាកងចល័តហ្នឹង ឧទាហរណ៍ក្នុងម៉ាស្រុកហ្នឹងវាបែងចែកតាមការដ្ឋានហ្នឹង វាមានកងចល័តហ្នឹង ម៉ាស្រុកហ្នឹងឧទាហរណ៍ថា វាមានម៉ាស្រុកហ្នឹងទាំងអស់រលីងម៉ាស្រុកហ្នឹង ឲ្យតែយុវជន ប៉ុន្តែមិនចូលទាំងអស់ទេ គេរើសម្តង១០-២០នាក់អីអញ្ចឹងទៅ ហើយទៅរើសស្រុកនោះ១០-២០នាក់ទៅចូលគ្នាអញ្ចឹងទៅ ស្រុក១០៩ ស្រុក១០៨ ស្រុក១០៦ ស្រុក៧ ស្រុក១០៥អញ្ចឹងម៉ោអាហ្នឹងគេបញ្ជូនម៉ោចូលម្តងហ្នង ។

ប៊ុនថន :	គេអត់មានកំណត់អាយុ កំណត់អីទេពូ?

នី :	អត់ទេ អត់មានកំណត់ទេ ឲ្យតែចេញពីយុវជនម៉ោលែងកំណត់ហើយ យុវជនវាមនុស្សពេញវ័យហើយ ។

ប៊ុនថន :	យុវជនអត់មានកំណត់ពីអាយុប៉ុន្មានដល់អាយុប៉ុន្មានទេ?

នី :	អត់ទេ ។

ប៊ុនថន :	អញ្ចឹងមើលលើរូបរាង?

នី :	ឲ្យតែធំប្រើការបាន វែកដីកើតទោះអាយុតិចយ៉ាងណាក៏ទៅដែរ ។

ប៊ុនថន :	លោកពូដូចបន្ទាប់ពីហាត់ហើយហ្នឹង ទៅប្រចាំការណ៍ហ្នឹងបាញ់គ្នាអញ្ចឹងពូមានខ្លាចទេ?

នី :	ទេបើយើងនិយាយរួមទៅ មិនថាភ័យមិនភ័យទេ វាត្រូវតែមានអាវុធឲ្យតែគេបាញ់ម៉ៅយើងភ័យវាម៉ោហើយ តែរួចភ័យយើងបាញ់គេវិញទៅ ។

ប៊ុនថន :	ភ័យដល់ពេលក្រោយម៉ោលែងភ័យហើយ?

នី :	លែងភ័យហើយ ព្រោះយើងកាន់អាវុធទៅមិនឃើញគេក៏ភ័យដែរ យើងទល់មុខគេហើយហ្នឹង គេនៅនោះយើងនៅនេះ យើងមានអារម្មណ៍មួយថាមិនដឹងពេលណាគេបាញ់យើង គេក៏អញ្ចឹងដែរគេអារម្មណ៍ដូចតែគ្នាហ្នឹង តែគេដាក់យើងពីងម៉ោយើងឮសូរកាំភ្លើងភ័យបាញ់បាត់ហើយ ភ័យចាំមើលហែងចេញច្រកណាសាកហែងវិញមើល៍ត្រង់ហ្នឹងដែលមើលប៉ាច់ដែលមើល៍ ។

ប៊ុនថន :	ប៉ុនដូចមុនគេទៅប្រចាំការណ៍គេមានបទបញ្ជាបទអីថា ឲ្យការពារប្ញម៉េចពូ?

នី :	អាហ្នឹងតែយើងចូលទៅក្នុងអង្គភាពទ័ពភ្លាមទៅ យើងមានកន្លែងហ្វឹកហ្វឺនគេបង្ហាត់យើងហើយ គេប្រាប់ពីរបៀបបច្ចេកទេស យើងត្រូវប្រុងប្រយ័ត្ន យើងត្រូវលូនយើងត្រូវ

ក្រាប យើងត្រូវធ្វើអាអ៊ីឲ្យមោះមុតអញ្ចឹងទៅ យើងដឹងហើយអាហ្នឹងបច្ចេកទេសតាមក្បួនរបស់គេគេប្រាប់ហើយ ។

ប៊ុនថន : ហើយលោកពូ ពេលពូទៅប្រចាំការណ៍ទពាំដែនហ្នឹង ដូចថាមានបទបញ្ជាពីលើថាត្រូវការពារកុំឲ្យពីណាចូលឬមួយម៉េចទេពូ?

នី : បាទ! អាហ្នឹងយើងត្រូវការពារដូចថា ខ្សែក្រវ៉ាត់ព្រំដែនយើងអញ្ចឹង តែគេម៉ោយើងត្រូវដាក់អញ្ចឹងហ្មង គេបញ្ជា ។

ប៊ុនថន : គេណែនាំយើង?

នី : បាទ! អាហ្នឹងគេបែងចែកដូចមានមេពួក មេក្រុមមេកងគេអញ្ចឹងទៅ មេគរមេកងគេអញ្ចឹងទៅ គេរៀបចាំត្រង់ហ្នឹង ហើយយើងចាំតែស្តាប់ទៅ គេមានគេអូរគ្រប់តែកន្លែងអញ្ចឹងទៅ ។

ប៊ុនថន : អាហ្នឹងគេថាម៉េចខ្លះពូបទបញ្ជាពេលហ្នឹង?

នី : តែនេះគេបញ្ជាថាឲ្យយើងឡើងទៅវៃ យើងត្រូវតែទៅ ឥឡូវគេវៃយើងហើយ យើងត្រូវម៉េចយើងត្រូវចាំបាញ់ឬក៏យើងមិនទាន់បាញ់ ឲ្យគេបាញ់ខាងនោះមុនអញ្ចឹងទៅ យើងនៅឲ្យស្ងៀមអញ្ចឹងមៅ យើងចាំត្រង់បាញ់គេពីនេះទៅ ដូនកាលគេបាញ់ពីខាងនោះមុនទៅៗ យើងនៅស្ងៀមសិនទៅអត់មានឲ្យផ្ទុះទាំងអស់ទេ អាហ្នឹងគេថាអាសត្រូវឲ្យវាចូលសិនអញ្ចឹង ដល់ចូលសិនម៉ោដល់ហើយ យើងដាក់ពឹងទៅអានោះចាក់ម៉ោឡើងបាញ់ទៅគេហៅខ្សែត្រៀម ខ្សែត្រៀមត្រង់ដូចខ្នែងក្របីអញ្ចឹង ខាងនោះដល់ពេលវាចូលម៉ោអញ្ចឹងអានោះបាញ់ដូងទៅ អានេះចេញម៉ោចេះម៉ោៗ យើងទយពីនេះទៅខ្ទប់ពីនេះទៅហ្មង អាហ្នឹងបច្ចេកទេសសត្រូវ ប៉ុនបើអូនឯងមិមធ្លាប់ ជំនាន់ហ្នឹងរឿងសត្រូវវាចេះទាំងអស់ហើយ តាំងពីជំនាន់សម្តេចនាយកក៏គាត់ដឹងដែរ គាត់ក៏មិនធម្មតាទេសុទ្ធអ្នកសត្រូវហើយ ។

ប៊ុនថន : អញ្ចឹងកងពូទទួល ឲ្យតែចូលម៉ោបាញ់ហ្មង?

នី : បាញ់ហ្មង ។

ប៊ុនថន : ប៉ុន្តែដែលចូលម៉ោខាង វៀតណាមអីដែលចូលទេ?

នី : ចូលៗបាញ់យើង យើងបាញ់វា យើងទប់វាមិនឈ្នះវាម៉ោទៅយើងដកថយទៅសិនប៉ុនយើងអត់មានឈ្មានពានទៅគេទេ យើងនៅការពារតែដីយើងទេ ប៉ុនបើវាចូលមៅយើងដាក់ហើយ ដាក់មិនឈ្នះរបើករបាញយើងរត់ទៅ ។

ប៊ុនថន ៖ មានដែលវ៉ៃគ្នាខ្លាំងទេលោកតូ?

នី ៖ ខ្លាំងពីសម័យហ្នឹងអូនឯងបើសិនជានៅមើលឃើញ យប់ឡើងមើលឃើញតែពេលផ្ទុះសន្ត្រាមបាត់គ្នាបុកម៉ោយើងហ្នឹង យាយពីភ្លើងមើលដូចផ្កា ដូចយើងគេធ្វើកាំជ្រួច អញ្ចឹងមើលឃើញភ្លើងព្រាកហ្នឹង យើងមើលពីចំងាយទៅឃើញភ្លើងព្រាកហ្នឹងអាភ្លើងធំអាភ្លើងតូចយើងបាញ់ដូចព្យុះអញ្ចឹង ។

ប៊ុនថន ៖ បាទ! មានស្លាប់ច្រើនទេលោកតូ?

នី ៖ អាហ្នឹងវា សំណាញ់តែចុះទឹកហើយរឿងអីមិនជាប់ត្រីជាប់ច្រវ៉ា បើមិនជាប់អីក៏ជាប់សំរាមដែរ នេះខ្ញុំនេះសុទ្ធតែត្រូវរបួស ជើងអីសុទ្ធតែត្រូវរបួស រុំម៉ោដល់ហ្នឹង ជាន់ចំរូងលិច ចុះពីលើទូកទៅដល់ ទៅលបបាញ់វាទៅដល់លបបាញ់វាហ្នឹង ដូចកន្លែងវានៅនោះអញ្ចឹងលបបាញ់វាកន្លែងលេនដ្ឋានវា ទៅដល់ចុះពីលើទូកមុតចំរូងក្លុច ចំរូងវាសុទ្ធចំរូងដែក ។

ប៊ុនថន ៖ តែពូមានដែលសម្រាកព្យាបាលពេទ្យអីទេពូ?

នី ៖ អាហ្នឹងយើងតែត្រូវរបួសយើងត្រូវថយម៉ោក្រោយ ច្បាប់ទម្លាប់ទ័ពគឺត្រូវអញ្ចឹង ឲ្យតែរបួសគឺត្រូវចេញម៉ោក្រោយ ត្រូវយកគ្នាចេញម៉ោក្រោយហើយឲ្យតែរបួស អត់មានទុកចោលនៅហ្នឹងទេ ដូចយើងមានពួកយើង៣នាក់អញ្ចឹង យើងត្រូវរបួសអញ្ចឹងម៉ោយើងរាយការណ៍ប្រាប់មេយើងបន្តថា ឥឡូវត្រូវរបួសមួយហើយ ត្រូវពីគ្រាប់ឬក៏ត្រូវពីចំរូងអញ្ចឹងទៅ យើងដកនាំកម្លាំងយើងចេញម៉ោ អ្នកនៅគេនៅសល់គេប្រយុទ្ធទៀតទៅ ។

ប៊ុនថន ៖ សម្រាប់ព្យាបាលរយៈពេលប៉ុន្មានពូ?

នី ៖ អាហ្នឹងគេយូរដែលហ្នឹង វាជួនកាលទៅយើងលឿនទៅវា ១ខែ-២ខែ បើយូរ៣ខែអីទៅតាមរបួសយើងវាធ្ងន់ស្រាល ។

ប៊ុនថន ៖ ព្យាបាលហ្នឹងគេជូនពូទៅព្យាបាលនៅណាវិញ?

នី ៖ នៅតាមអង្គភាពគេហ្នឹង បើយើងធ្ងន់ម៉ោតាមមន្ទីរពេទ្យគេតាមស្រុក តាមខេត្តអញ្ចឹងទៅតាមតំបន់អញ្ចឹងទៅ ប៉ុនមុនគេអត់ហៅខេត្តទេ គេហៅតំបន់ ។

ប៊ុនថន ៖ បាទ! មន្ទីរពេទ្យតំបន់ហ្នឹងកាលហ្នឹងនៅណាវិញពូ?

នី ៖ ទេ! បើនិយាយរួមទៅខ្ញុំអត់បានចូលដល់តំបន់ផងមន្ទីរពេទ្យគេ យើងមានតែតាមអង្គភាពហើយនឹងតាមស្រុកយើងហ្នឹង ។

ប៊ុនថន ៖ ស្រុកគិរីវង្ស?

នី ៖ បាទ! តាមមន្ទីរពេទ្យស្រុកអញ្ចឹងទៅ ។

ប៊ុនថន ៖ កាលហ្នឹងពីណាប្រធានមន្ទីរពេទ្យពូ?

នី ៖ យី!ដូចអត់បានតាមដាន យើងអត់បានចាប់អារម្មណ៍ពីឈ្មោះអ្នកនេះអី ឈ្មោះអ្នកនោះអីផង ។

ប៊ុនថន ៖ បាទ!អញ្ចឹងពូនៅតែខាងទ័ព?

នី ៖ បាទ! យើងនៅខាងមុខដឹងតែខាងមុខអញ្ចឹងទៅ មុខហ្នឹងយើងដឹងតែមិនទាន់គ្រប់ប៉ុន្មានទេបើនិយាយរួមទៅ ដឹងតែអ្នកណានៅកៀកយើង យើងដឹងតែហ្នឹងមេទៅ ហើយដល់ពេលទៅនោះ យើងដឹងតែមេធំៗត្រឹមវរៈសេនាធំចុះមកក្រោមម៉ោ ដល់ពេលកងពលមិនដឹងអ្នកណាជាអ្នកណាទេ មិនដែលបានទៅជងយើង គេមិនឲ្យចូលកន្លែងគេទេ ទោះបីយើងទ័ពដូចគ្នាមែន តែយើងមិនអាចទៅចូលកន្លែងកងពលបានដែរ ចូលបានតែវរៈសេនាធំអីគេនោះបានចូលបាន ហើយនឹងប្រធានវរៈគេទេបានចូលបាន ។

ប៊ុនថន ៖ វរៈសេនាធំឈ្មោះអីវិញពូ?

នី ៖ ឈ្មោះតានាគ ។

ប៊ុនថន ៖ តានាគ?

នី ៖ បាទ! មិនដឹងស្អីនាគទេ ប៉ុនដឹងតែឈ្មោះតានាគៗ វរៈសេនាធំ១៦ ។

ប៊ុនថន ៖ អាហ្នឹងមេបញ្ជាការរបស់ពូហ្នឹង?

នី ៖ បាទ! មេបញ្ជាការធំហ្នឹង ។

ប៊ុនថន ៖ ហើយលោកពូដែលវ៉ៃបន្ទាយវៀណាម បែកខាងវៀតណាមទេ?

នី ៖ ខ្ញុំអត់ដែលចូលវ៉ៃទេ អត់សោះយើងនៅតែខ្សែត្រៀម គ្រាន់តែគេបាញ់ម៉ោ យើងបាញ់គេទៅ បាញ់តទៅតម៉ោអត់មានលុកទៅលុកម៉ោទេ ជួនកាលកន្លែងខ្លះអង្គភាពខ្លះគេចូលទៅបាញ់នៅក្នុងវ៉ៃនៅក្នុង ។

ប៊ុនថន ៖ ហើយដែលបែកទេ បែកខាងវៀតណាមទេ?

នី ៖ បែកប៉ុនយើងដកដដែលហ្នឹង អត់មាននៅឈរជើងទេ ទៅវ៉ៃកំទេចចោលហើយដកម៉ោវិញដដែលហ្នឹង បន្ទាយមិនដឹងប៉ុន្មានទេ ទៅវ៉ៃអាបន្ទាយហ្នឹងទៅ រត់របាត់របាយយើងនាំគ្នាដក់ម៉ោវិញម៉ោ ភ្លឺយើងដកម៉ោវិញម៉ោគេហៅថា សង្គ្រាមឈ្លប យើងមិនមែន

សង្គ្រាមយើងបុកយកប្រទេសមួយទាំងមូលអី ក្នុងតាមតំបន់ណាមួយៗអត់ទេ យើងគ្រាន់តែទៅលបវ៉ៃឈ្លបអីហ្នឹង ។

ប៊ុនថន : វ៉ៃហើយដក?

នី : បាទ! វ៉ៃហើយដក ។

ប៊ុនថន : ប៉ុនខាងវៀតណាមដែលវ៉ៃចូលម៉ោខ្មែរទេ?

នី : ដល់ចុងក្រោយវ៉ៃម៉ោបណ្ដោយ ម៉ោរហូតបណ្ដោយហ្នឹង អាហ្នឹងរឿងរាជរដ្ឋាភិបាលយើងមេធំៗទំនាក់ទំនងគ្នាយ៉ាងម៉េចឬយ៉ាងណាមួយរឿងផ្ទៃក្នុងយើងអត់ដឹងទេ យើងដឹងតែធ្វើទ័ពយើងធ្វើទ័ពហ្នឹង យើងបាញ់គេរត់ យួនដេញយើងរត់អញ្ចឹងម៉ោ ។

ប៊ុនថន : លោកពូនៅនោះនៅជាមួយគានាគហ្នឹង នៅរហូតឬក៏មានផ្លាស់ប្ដូរទៅ?

នី : អត់មានទៅណាទេអូន ដល់យើងរត់ម៉ោបាក់ទ័ពម៉ោទាំងអស់គ្នាម៉ោហ្នុង ម៉ោកងខ្ញុំហ្នឹងអង្គភាពខ្ញុំហ្នឹងគេម៉ោៗ ខ្ញុំទៅនោះដាច់មាកង់ទៅនោះទៅ បែកគ្នាអស់ ។

ប៊ុនថន : ដាច់ទៅខាងណាវិញលោកពូ?

នី : យើងទៅស្រុកវិញទៅ ។

ប៊ុនថន : ត្រឡប់ទៅស្រុកវិញ?

នី : បាទ! យើងឈប់ធ្វើទ័ពធ្វើអីទៅស្រុកគេឯង អត់មានកាន់អាវុធកាន់អីទៀតទេ នៅអំណាចលើគេរៀបភូមិ ឃុំអីយើងផ្សេងទៀតហើយ គេធ្វើអីសម័យសាមគ្គីនោះ ។

ប៊ុនថន : អញ្ចឹងតាំងពីវៀតណាមវ៉ៃចូលហ្នឹង ពូរត់ត្រឡប់ទៅស្រុកវិញ?

នី : ទៅស្រុកវិញ ។

ប៊ុនថន : ហើយគានាគហ្នឹង?

នី : គានាគ ម៉ោនេះម៉ោនាំគ្នាម៉ោចេះម៉ោគេរៀបអង្គភាពគទៅទៀតទៅ មិនដឹងទៅដល់ណាដល់ណីទេឆាប់រស់ម៉េចយើងអត់ដឹងដែរ ។

ប៊ុនថន : បាទ! ត្រឡប់ទៅស្រុកវិញហ្នឹងពូធ្វើអីទៀត ពេលទៅដល់ស្រុក?

នី : ទៅដល់ស្រួលបួលយើងធ្វើទ័ពគេ ។

ប៊ុនថន : ធ្វើទ័ព?

នី : បាទ! ទ័ពយើង ប៉ុនយើងគ្រាន់ថា មួយខាងខ្មែរក្រហមផ្ដាច់ខ្លួនហើយ ផ្ដាច់ខ្លួនម៉ោខាងនេះមួយសារម៉ោ ក្រុមខ្មែរក្រហមនេះយើងទៅធ្វើខាងរដ្ឋកម្ពុជាទៅ ។

ប៊ុនថន : បាទ! ខាងរដ្ឋកម្ពុជាវិញ?

នី ៖ បាទ! ទ័ពនៅតែទ័ពដដែលហ្នឹង រដ្ឋកម្ពុជានៅតែធ្វើហ្នឹង ខាងណាក៏មិនថាដែរឲ្យតែជាតិខ្មែរ ព្រោះយើងនៅក្រោមគេហៅថា អាណាព្យាបាលរបស់រាជរដ្ឋាភិបាលទាំងអស់ ខាងណាក៏យើងធ្វើដែរ យើងអត់មានចាត់ទុកយើងជាអ្វីមួយអត់ទេ ។

ប៊ុនថន ៖ ចូលដំបូងពូម៉ោហាត់ទៀតពូ?

នី ៖ ហាត់ទៀត នៅតែហាត់បន្តទៀតអញ្ចឹងហ្នង តែរៀបចំទ័ពថ្មីដឹងតែហាត់អញ្ចឹងរហូតហ្នង គេមិនថាយើងចេះមិនចេះទេ គេរៀបក្បួនខ្លាតគេថ្មីចាស់អីក៏តែដូចតែគ្នា ប៉ុននៅតែហាត់ដដែលហ្នឹង នៅតែយើងទ័ពថ្មីដដែលហ្នឹង យើងទៅជាមេពួកអញ្ចឹងទៅៗ មេក្រុមអញ្ចឹងទៅ ចេញពីក្រុមទៅមេ"ខ"អញ្ចឹងទៅ ។

ប៊ុនថន ៖ ពូបានមេ"ខ"ដែរ?

នី ៖ បាទ!បានមេ"ខ"គេដែរ ។

ប៊ុនថន ៖ មេ"ខ"ហ្នឹងគេគ្រប់គ្រងទ័ពប៉ុន្មាននាក់ៗទៅ?

នី ៖ អាហ្នឹងមើស៎!ខ្ញុំរៀបរាប់ ទី១ពួកហ្នឹងក្តាប់៣នាក់ ដល់ពេលក្រុមម៉ោកាន់គ្នា១២នាក់ ដល់"ខ"ហ្នឹងម៉ោវាក្តាប់អា១២នាក់ហ្នឹងមានប៉ុន្មានអញ្ចឹងទៅ បន្តគ្នាទៀតទៅគ្រងគ្នា តាម ។

ប៊ុនថន ៖ "ខ" ហ្នឹងបានគ្នាប៉ុន្មាននាក់ពូ?

នី ៖ "ខ"ហ្នឹងបើយើងសរុបមើស៎! តាមកម្លាំងទ័ពតិចទ័ពច្រើនយកមកចូល ចាប់ពី៣០នាក់អីអញ្ចឹងទៅ ២៥នាក់ទៅតាមតិចតាមច្រើនអញ្ចឹងទៅ ប៉ុនឈ្មោះយើងវាត្រូវនៅ"ខ"ហ្នឹង ។

ប៊ុនថន ៖ ចុះពូអត់មានឡើងលើ"ខ"ទៀតទេពូ?

នី ៖ អត់ទេ ។

ប៊ុនថន ៖ បាទ!តែត្រឹមហ្នឹងទេ?

នី ៖ ត្រឹមហ្នឹង ។

ប៊ុនថន ៖ បាទ!ចុះបញ្ជូនម៉ោហាត់ហ្នឹង ហាត់នៅណាវិញលោកពូ?

នី ៖ ហាត់នៅយើងស្ទឹងប្រាលនេះ ។

ប៊ុនថន ៖ ស្ទឹងប្រាល?

នី ៖ ស្ទឹងប្រាល កោះកញ្ជោរខេត្តកំពង់ស្ពឺ ដាច់ដោយឡែកផ្លូវជាតិលេខ៤នេះ ផ្លូវកំពង់សោមនោះមុំដោះកញ្ជោរដោះអីហ្នឹង ។

ប៊ុនថន ៖ ហាត់យូរទេពូ?

នី : ហាត់ច្បាប់ទ័ព៣-៦ខែនោះ តាមជំនាញគេបង្ហាត់អាហ្នឹង ។

ប៊ុនថន : បាទ! ហើយហាត់ហ្នឹងរយៈពេលយូរទេ?

នី : ហាត់កំណត់ម៉ោងដូចតែយើងដែរហ្នឹង ពីម៉ោង៧រហូតដល់ម៉ោង១០ អីអញ្ចឹងយើងសម្រាក១១អីយើងសម្រាកម៉ោ ។

ប៊ុនថន : បាទ!អត់ទេយូរខែទេ?

នី : វាដូចខ្ញុំថាមិញអញ្ចឹង ៣ទៅ៦ខែអីទៅ ។

ប៊ុនថន : បាទ! ហើយមានឡើងម៉ោវៃ?

នី : អត់មានឡើងម៉ោវៃទេ អត់ទាន់វៃទេកាលហ្នឹងនោះ យើងនៅការពារអគ្គភាពយើង អត់មានដើរទៅវៃនៅណាទេ ចុះអូរដើរលុកលុយព្រៃអញ្ចឹងទៅ រកខ្មែរក្រហមរកអីអញ្ចឹងទៅ ប៉ុរកក៏គេមិនទាន់មានជួបគ្នាបាញ់គ្នាដែរអត់មានទេ គ្រាន់តែរកទេ ដើរទៅយើងវិលម៉ោវិញម៉ោ អញ្ចឹងទេខ្ញុំចុះទៅគីរីរម្យម៉ោឡានយើងទៅៗ ទៅសម្រាកហ្នឹងឧទាហរណ៍គេដាក់ផែនការណ៍ប៉ុន្មាន កន្លះខែ ១០ថ្ងៃអញ្ចឹងទៅយើងត្រូវវិលម៉ោវិញ ម៉ោទៅជួបជាមួយប្រជាពលរដ្ឋនៅចំការតែអញ្ចឹងទៅ បាញ់សត្វបាញ់អីហូបអញ្ចឹងទៅពួកយើងរៀបខ្សែត្រៀមទុកទៅ ការពារខ្លាចខ្មែរក្រហមបាញ់យើងវិញ ។

ប៊ុនថន : បាទ! ហើយអត់ដែលមានប៉ះគ្នា?

នី : អត់ដែលប៉ះគ្នាទេ ។

ប៊ុនថន : អញ្ចឹងពូនៅខាងក្រោយវិញទេ អត់នៅខាងជួរមុខទេ?

នី : អាហ្នឹងវាអត់មានមុខមានក្រោយទេ បើនិយាយរួមពីជំនាន់ហ្នឹងគេអត់មានមុខមានក្រោយទេ បើមានៗម៉ាជួរយើងនៅនេះប៉ុនមានមុខ ម៉ាជួរ៥៦យើងនេះ ។

ប៊ុនថន : ជួរ៥៦នេះ?

នី : បាទ!ជួរ៥៦ ដល់ពេលអញ្ចឹងទៅគេបំបែកទ័ពម៉ាសារហ្នឹង កងពលខ្ញុំគេបំបែកម៉ោ៥៦ នេះ កងពលលេខ២ហ្នឹងយក៥៦ម៉ោទាំងអស់ ដល់៥៦ទាំងអស់ហ្នឹងខ្ញុំទៅនៅរៀន នៅរៀននៅយើងដំបូលបែកចាននេះ សាលា៥៦-៥៧ហ្នឹងគេរៀនពួកចាស់ៗជំនាញ មុនៗគេអញ្ចឹង ហើយគេបញ្ជូនទ័ពម៉ោនេះម៉ោ ហើយយើងនៅរៀនហ្នឹង ។

ប៊ុនថន : បាទ! អញ្ចឹងពូអត់បានម៉ោ៥៦គេទេ?

នី : អត់បានទេ ។

ប៊ុនថន ៖ កាលហ្នឹង៩៦អ្នកណា អ្នកដឹកនាំពូខាង?

នី ៖ កាលហ្នឹងប្រធានកងពលគេ ហ៊ុយ វណ្ណា ។

ប៊ុនថន ៖ ហ៊ុយ វណ្ណា?

នី ៖ បាទៗ! ប្រធានកងពល ។

ប៊ុនថន ៖ ចុះខាងខ្មែរក្រហមពូមានដឹងថាខាងណាអ្នកដឹកនាំ?

នី ៖ ខ្ញុំភ្លាប់អត់ជុំ ខ្មែរក្រហមខ្ញុំភ្លាប់អត់ជុំទេ ព្រោះយើងដឹងតែក្នុងវង្វង់ ឧទាហរណ៍ថា បើយើងផ្ទះជិតៗគ្នាយើងចេះតែដឹង តែរឿងសង្គ្រាមយើងអត់ដឹងទេ បើមេៗចេះតែដឹងថាណាណី នៅតាមគេអូរអញ្ចឹងទៅ យើងចេះតែដឹង នយោបាយផ្ទៃក្នុងសង្គ្រាមម៉េចៗយើងអត់ដឹងទេ យើងដឹងតែធ្វើសង្គ្រាមៗហ្នឹង ទ័ពៗហ្នឹងអានេះកំរិតយើងនៅក្រោមយើងអត់ដឹងអីទេ ។

ប៊ុនថន ៖ បាទ!អញ្ចឹងលោកពូនៅទ័ពខាងក្នុងនេះរហូតពូ?

នី ៖ រហូតដែរ ។ យូរទៅខាងនេះក៏នៅ ខាងនោះក៏នៅ មុនខាងនេះ ដល់ពេលយើងទៅដល់នោះទៅនៅខាងនោះវិញ ធ្វើទ័ពវិញរហូត ។

ប៊ុនថន ៖ បាទ! ធ្វើទ័ពខាងក្នុងនោះរហូតមកដល់?

នី ៖ បាទ! រហូត ។

ប៊ុនថន ៖ រហូតមកដល់សព្វថ្ងៃហ្នឹងលោកពូ?

នី ៖ មិនទេ! មិនដល់សព្វថ្ងៃនេះទេ យើងឈប់ធ្វើទ័ពហ្នឹងយើង៨៣-៨៤ហើយ ឈប់ធ្វើទ័ពមានប្រពន្ធហើយ រកប្រពន្ធកូនខ្ញុំ មានគ្រួសារហើយ គ្រួសារធ្វើស្រែធ្វើចំការវិញហើយអត់មានធ្វើទ័ពអីទៀតទេ ។

ប៊ុនថន ៖ អាហ្នឹងត្រឡប់ទៅស្រុកវិញពូ?

នី ៖ បាទ! ត្រឡប់ទៅស្រុកវិញហើយ ។

ប៊ុនថន ៖ ឆ្នាំ៨៤ពូឈប់?

នី ៖ បាទ! ខ្ញុំម៉ោយូរឆ្នាំហើយ ឆ្នាំ២០១១ហើយ ។

ប៊ុនថន ៖ ចុះពូម៉ោនៅនេះនៅឆ្នាំប៉ុន្មានដែរពូ?

នី ៖ ខ្ញុំម៉ោនៅនេះវាឆ្នាំ២០០៩ ម៉ោមានប្រពន្ធនៅស្រុកនេះ ។ មិនមាននៅស្រុកទេ នៅស្រុកបាកាននោះ ។

ប៊ុនថន ៖ ស្រុកបាកាន?

នី ៖ បាទ!

ប៊ុនថន ៖ អញ្ចឹងពូមានប្រពន្ធ២ដង?

នី ៖ បាទ! មានប្រពន្ធ២ដង មានគ្រួសារ២ដង ។

ប៊ុនថន ៖ នៅបាកានហើយ បានម៉ោនេះ២០០៩ពូ?

នី ៖ បាទៗ!

ប៊ុនថន ៖ ចុះឥឡូវនេះពូនៅភូមិអីដែរ?

នី ៖ ឥឡូវនេះ បច្ចុប្បន្ននេះ?

ប៊ុនថន ៖ បាទ?

នី ៖ នៅភូមិប្រមោយ ឃុំប្រមោយ ស្រុកវាលវែង ។

ប៊ុនថន ៖ បាទ! ចុះយ៉ាងម៉េចបានពូម៉ោនៅនេះពូ?

នី ៖ យើងវានៅនោះដីវាចេះតែចង្អៀត ដល់ពេលអញ្ចឹងទៅរាជរដ្ឋាភិបាលយើងបង្កើត ស្រុកថ្មី យើងចេះតែរក ចុះយើងកូនច្រើនដែរមិនអញ្ចឹង យើងដូរដីដូរធ្វើទៅក្រែងលរ វាទូលំទូលាយអញ្ចឹងណាស់ ហើយម្លោះហើយរាជរដ្ឋាភិបាលយើងរៀបចំផ្លូវអីស្រួល បួលហ្នឹងយើងចេះតែនាំកូនចៅយើងម៉ោ ធ្វើស្រែធ្វើចំការអញ្ចឹង ហើយដល់ឥឡូវ យើងបានធ្វើស្រែធ្វើចំការទៅ យើងវាមិនទាន់ថាធូរធារយ៉ាងណាទេ អានេះសំខាន់ បំផុតនៅលើយើងខំប្រឹងខ្លួនឯង ប៉ុនអារឿងច្បាប់ទម្លាប់អីយើងបានធូរធារគ្រាន់ថា មានសិទ្ធិសេរីភាពអញ្ចឹងដែរ ។

ប៊ុនថន ៖ បាទ! ប៉ុន្មានកូនសព្វថ្ងៃ?

នី ៖ ខ្ញុំ៧នាក់នោះ រៀបការហើយ២នាក់ នៅ៥នាក់សុទ្ធតែធ្វើចំការធ្វើស្រែហ្នឹង ។

ប៊ុនថន ៖ ចុះពូដូចម៉ោដល់ដំបូងហ្នឹង ភូមិសាស្ត្រយ៉ាងម៉េចដែរពូ កាលឆ្នាំ២០០៩ហ្នឹង ដូចមាន មនុស្សមករស់នៅច្រើនទេ?

នី ៖ ២០០៩-២០១០ ម៉ោដល់ស្រុកវាលវែង២០១០ហើយខ្ញុំ ខ្ញុំនៅស្រុកបាកាន ២០០៩ ។

ប៊ុនថន ៖ អូ!ទើបថ្មីៗដែរ?

នី ៖ បាទ!មកដល់២០១០ ។ អេ៎! ២០១០អី អេ៎!ច្រលំសំដីហើយ ច្រលំពាក្យហើយ អា២០១០ទើបឥឡូវៗនេះ តាំងពី៩០ដំបូងម៉ោ ខ្ញុំការបានមួយឆ្នាំបានខ្ញុំម៉ោ ឆ្នាំ ១៩០០ប៉ុន្មានទេភ្លេចហើយ ។

ប៊ុនថន : សមាហរណកម្មឬនៅពូ?

នី : ហើយៗ យើងបង្កើតស្រុកនេះ ។

ប៊ុនថន : ហើយៗប្រហែលជាប៉ុន្មានឆ្នាំពូ?

នី : ជាង១០ឆ្នាំហើយខ្ញុំម៉ោនៅនេះ ។

ប៊ុនថន : អញ្ចឹងមានន័យថាក្រោយសមាហរណកម្ម សមាហរណកម្មឆ្នាំប៉ុន្មានពូនៅនេះ ៩៦?

នី : បាទ!៩៦ ។

ប៊ុនថន : បាទ!៩៦-៩៧?

នី : ៩៨-៩៩ ។

ប៊ុនថន : ៩៩ពូ?

នី : បាទៗ!ដាក់ឆ្នាំ៩៩ ច្រលំអាភាសាយើងនិយាយឥឡូវនេះ យើងយកពាក្យឥឡូវនេះយកប្រើ ។

ប៊ុនថន : ចុះពូម៉ោនៅនេះដំបូងដូចថាមានប្រជាជនរស់នៅច្រើនទេ ហើយការបែងចែកដីធ្លីអីយ៉ាងម៉េចដែរនៅហ្នឹង?

នី : អេ៎!ដំបូងម៉ោគ្មានទាន់មានទេនៅនេះ ប្រជាពលរដ្ឋនៅតិចណាស់ នៅនេះមានតែផ្ទះ ៣-៤ទេ បើនិយាយពីភូមិប្រទាលជ្រុំមាន៣-៤-៥គ្រួសារហ្នឹង ហើយប្រមោយនោះមានប្រហែលខ្ទង់១០ទៅ២០គ្រួសារទេ បើខាងត្បូងស៊ីងមាន៤-៥គ្រួសារអញ្ចឹង ទៅមាននៅវង្វង់មូលមាន-៧គ្រួសារអញ្ចឹងទៅ នៅតាពរនោះផ្សេងនៅតាមភូមិៗគេម្តុំៗអញ្ចឹង អត់ទាន់មានប្រជាពលរដ្ឋច្រើនអញ្ចឹងទេនៅតិចដែរទេ ។

ប៊ុនថន : បាទ!ចុះដីធ្លីបែងចែកម៉េចដែរពូ?

នី : ដីធ្លីយើងកាលម៉ោដំបូងវានៅទូលំទូលាយ យើងចេះតែក្នុងស្រុកក្នុងឃុំអីទៅ ហើយភូមិហ្នឹងយើងចេះតែសុំអីគ្នាឯងអញ្ចឹង សុំរំលែកគ្នាឯងដោយឥតមានថវិកាទេ ។

ប៊ុនថន : បាទ! សុំដីធ្វើស្រែធ្វើចំការ?

នី : បាទៗ! បែងចែកគ្នាធ្វើអញ្ចឹង ប៉ុន្តែគ្រាន់តែថាកន្លែងគេហើយមុនហើយទៅ យើងក្រោយអ្នកចាស់ៗគេបានមុនអញ្ចឹង យើងអ្នកក្រោយបានក្រោយអញ្ចឹង តៗគ្នា ។

ប៊ុនថន : ហើយគេធ្វើអីដែរ ភាគច្រើនពូ?

នី : ធ្វើចំការស្រុកនេះ ភាគច្រើនធ្វើចំការហ្នឹងហ្មងស្រុកហ្នឹង អត់មានធ្វើស្រែអីទេ ធ្វើតែចំការហ្មង ។

ប៊ុនថន : ចុះបានផលលក់ទៅខាងណាវិញ?

នី : យើងបើនិយាយជារួមពីមុនម៉ោយើងធ្វើគ្មានគិតជាលក់ដូរអីទេ យើងធ្វើសម្រាប់តែហូបទេ ដល់ឥឡូវហ្នឹងមានលក់ដូរ ដូចយើងដាំពោត ដាំសណ្តែក មានលក់នៅតាមទី ផ្សារ គេឲ្យតំលៃប៉ុន្មានយើងលក់ប៉ុនហ្នឹងគេ យើងលក់តាមហាងឆេង ម៉ាគីឡូប៉ុន្មានយើងលក់តាមគេឯង លក់ពោត លក់ល្ងរអញ្ចឹងទៅ។

ប៊ុនថន : ចង់សួរលោកពូមួយទៀតដូចភូមិ ឃុំអីគេបែងចែកក្រោយសមាហរណកម្មហើយឬក៏?

នី : ដាក់ក្រោយទេ។

ប៊ុនថន : កាលមុនគេហៅវាលវែងទេ ?

នី : បាទ! អាហ្នឹងហៅតាមជាប់ៗពាក្យពីបរមបុរាណម៉ោ គេហៅវាលវែងៗ ស្រុកវាលវែងនៅនោះទេ។

ប៊ុនថន : នៅណាពូ?

នី : នៅអូរសោមនោះទេ អញ្ចឹងដល់ស្រុកយើងនឹងវាលវែងគេយកស្រុកម៉ោដាក់ធ្វើជាសាលាស្រុកនៅប្រមោយនេះហ្នង ហ្នឹងលើកយកជាចង្កោមជាស្រុកវាលវែងហ្នឹងម៉ោក្រោយម៉ោបានដាក់នៅក្នុងស្រុកហ្នឹង បើវាលវែងនៅនោះទេ នៅអូរសោម។

ប៊ុនថន : ពូចុងក្រោយខ្ញុំសួរពូទាក់ទងជាមួយតុលាការអញ្ចឹង ដូចពូធ្លាប់ឆ្លងកាត់ ដូចថាធ្លាប់បំរើឲ្យរបបខ្មែរក្រហមផង ឲ្យខាងរដ្ឋាភិបាលភ្នំពេញផង ឥឡូវហ្នឹងមានការកាត់ទោសខ្មែរក្រហមអីអញ្ចឹងលោកពូ ហើយពូយល់យ៉ាងម៉េចដែរពូតាមគំនិតពូ?

នី : ទេ! បើនិយាយពីអាកាត់ទោស កាត់អីនេះយើងប្រជាពលរដ្ឋយើងមិនអាចដឹងថាយ៉ាងម៉េច យើងមិនអាចឲ្យតំលៃថាយ៉ាងណាទេ អាហ្នឹងបើនិយាយឲ្យដល់ យើងជាប្រជាពលរដ្ឋអាកាវិនិច្ឆ័យវាយតំលៃកាត់ទោសហ្នឹង យើងអត់ដឹងថាគាត់ហ្នឹងវាអ្នកទោសហ្នឹងឈ្មោះណាឈ្មោះណី វាត្រូវកំរិតណាយើងអត់បានដឹងដែរអាហ្នឹង វានៅលើរាជរដ្ឋាភិបាលហើយអាហ្នឹង យើងអត់ដឹងដែរដឹងត្រឹមណាយើងនិយាយត្រឹមហ្នឹងទៅ។

ប៊ុនថន : បាទៗ! អញ្ចឹងខ្ញុំអស់មានអីសួរហើយ ខ្ញុំអរគុណលោកពូច្រើន។

នី : បាទ!

ចប់